**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 05PR-26/EoJ 6 February 2026

## Japan Provides US$301,904 for Irrigation Facility Rehabilitation, the Construction of a Dormitory for Female Students and the Installment of Vocational Training Equipment

The Government of Japan will provide a total of US$301,904 to two recipient organizations under *the Grant Assistance for Grassroots Human Security Projects ("KUSANONE")* framework. The Grant Contracts for the following two projects were signed today by H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the two recipient organizations.

**1. 'Project for the Rehabilitation of Ou Srolao Chhrom Irrigation Facilities in Banteay Meanchey Province' (US$220,216)**

Recipient: Banteay Meanchey Provincial Department of Water Resources and Meteorology

This grant will be used to rehabilitate existing irrigation facilities where reservoir functionality is currently inadequate. This area is drought-prone during the dry season because the irrigation infrastructure doesn't capture and store an adequate amount of water during the rainy season. Moreover, there is no sluice gate in the most appropriate location for one. This has made it more difficult to efficiently distribute water to agricultural fields. Through the improvement of irrigation facilities, the project is expected to secure a stable supply of agricultural water throughout the year and benefit more than 6,000 local residents, including those who have returned from Thailand as a result of the border conflicts between Cambodia and Thailand.

**2. 'Project for the Construction of a Female Student Dormitory and the Installment of Vocational Training Equipment at Mondulkiri Provincial Training Center' (US$81,688)**

Recipient: Mondulkiri Provincial Training Center

This grant will be used to construct a dormitory for female students and provide vocational training equipment. The dormitory will provide female students with a comfortable place to stay and the new equipment will give all of the students the opportunity to learn the kinds of vocational skills that will help them to find work after graduation. This project will, therefore,

lead to an improvement in the standard of living for the residents in the area.

Japan's "KUSANONE" Projects started in Cambodia in 1991 with the aim of supporting Cambodia's reconstruction and development at the grassroots level. The "KUSANONE" assistance projects aim to protect those who are vulnerable as a result of factors, such as poverty and/or misfortune, that are directly threatening their lives, livelihoods, and dignity. The "KUSANONE" assistance also focusses on developing the self-reliance of local communities. Since 1991, the Government of Japan has provided over US$72 million, mainly to local authorities and non-governmental organizations, to assist them with the implementation of over 700 KUSANONE projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 05PR-26/EoJ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៦

# ជប៉ុនផ្តល់ថវិកា ៣០១,៩០៤ ដុល្លារអាមេរិក សម្រាប់ការស្តារប្រព័ន្ធធារាសាស្រ្ត និងការសាងសង់អន្តេវាសិកដ្ឋាននិស្សិតស្រី និងតម្លើងឧបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈ

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន ៣០១,៩០៤ ដុល្លារអាមេរិក ដល់ស្ថាប័នទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយចំនួនពីរ។

## ១. គម្រោងស្តារប្រព័ន្ធធារាសាស្រ្តអូរស្រឡៅជ្រុំក្នុងខេត្តបន្ទាយមានជ័យ (ថវិកាចំនួន ២២០,២១៦ ដុល្លារអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ

ជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីស្តារប្រព័ន្ធធារាសាស្រ្តមានស្រាប់ ដែលមានមុខងារអាងស្តុកទឹកអន់ថយ។ តំបន់នេះងាយរងគ្រោះរាំងស្ងួតក្នុងរដូវប្រាំង ដោយសារប្រព័ន្ធធារាសាស្រ្តមិនអាចស្តុកទឹកបានគ្រប់គ្រាន់ក្នុងរដូវវស្សា។ បន្ថែមពីនេះទៅទៀតគឺពុំមានទ្វារទឹកនៅទីតាំងសមស្របឡើយ។ កត្តានេះបានធ្វើឱ្យមានការលំបាកក្នុងការផ្គត់ផ្គង់ទឹកឱ្យមានប្រសិទ្ធភាពសម្រាប់វិស័យកសិកម្ម។ តាមរយៈការកែលម្អប្រព័ន្ធធារាសាស្រ្ត យើងរំពឹងថាគម្រោងនេះ នឹងធានាបាននូវការផ្គត់ផ្គង់ទឹកសម្រាប់កសិកម្មប្រកបដោយស្ថិរភាពពេញមួយឆ្នាំ និងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនមូលដ្ឋានប្រមាណ ៦,០០០នាក់ រួមទាំងអ្នកដែលបានត្រឡប់មកពីប្រទេសថៃវិញ ដោយសារជម្លោះព្រំដែនរវាងកម្ពុជា និងថៃ។

## ២. គម្រោងសាងសង់អន្តេវាសិកដ្ឋាននិស្សិតស្រី និងតម្លើងឧបករណ៍នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី (ថវិកាចំនួន ៨១,៦៨៨ ដុល្លារអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី

ជំនួយនេះនឹងត្រូវបានប្រើប្រាស់សម្រាប់សាងសង់អន្តេវាសិកដ្ឋាននិស្សិតស្រី ក៏ដូចជាផ្តល់ឧបករណ៍ប

ណ្តុះបណ្តាលវិជ្ជាជីវៈ។ អន្តេវាសិកដ្ឋាននឹងផ្តល់ឱ្យនិស្សិតស្រីនូវកន្លែងស្នាក់នៅប្រកបដោយផាសុកភាព ហើយឧបករណ៍ថ្មីនឹងផ្តល់ឱ្យនិស្សិតទាំងអស់នូវឱកាស ដើម្បីរៀននូវជំនាញវិជ្ជាជីវៈនានា ដែលនឹងជួយពួកគេក្នុងការស្វែងរកការងារបន្ទាប់ពីបញ្ចប់ការសិក្សា។ ដូចនេះ គម្រោងនេះនឹងនាំមកនូវការកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់។

គម្រោងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងគូសាណូណិ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។ ជំនួយឥតសំណងគូសាណូណិក៏ផ្តោតលើការអភិវឌ្ឍនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៧២លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីគាំទ្រពួកគេក្នុងការអនុវត្តគម្រោងគូសាណូណិជាង ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង**
**សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**ថ្ងៃ០៦ ខែកុម្ភៈ ឆ្នាំ២០២៦**

សូមគោរព

- **ឯកឧត្តម តាំង ផេងរិទ្ធី** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **លោក ឌឹម នី** អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី
- **លោក កោ គីមអាន** នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី
- **លោក ឡាយ សុទ្ធី** ប្រធានស្តីទីមន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

អរុណសួស្តី និងសូមស្វាគមន៍មកកាន់ស្ថានទូតជប៉ុន។ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយឥតសំណង ដែលនឹងត្រូវបានអនុវត្តក្រោមគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

ជាដំបូង សូមអនុញ្ញាតឱ្យខ្ញុំនិយាយដោយសង្ខេបអំពីជម្លោះព្រំដែនរវាងកម្ពុជានិងថៃ។ រដ្ឋាភិបាលជប៉ុន និងរូបខ្ញុំផ្ទាល់ ស្វាគមន៍ការសម្រេចបាននូវកិច្ចព្រមព្រៀងបទឈប់បាញ់លើកទី២ និងការវិលត្រឡប់មកវិញដោយសុវត្ថិភាពរបស់ទាហានកម្ពុជាទាំង១៨រូប នៅមុនដំណាច់ឆ្នាំកន្លងទៅ។ រដ្ឋាភិបាលជប៉ុននឹងបន្តផ្តួចផ្តើមការគាំទ្រនានា ដើម្បីកាត់បន្ថយភាពតានតឹងបន្ថែមទៀត ក៏ដូចជាផ្តល់នូវជំនួយផ្សេងៗ។

ខ្ញុំសុំត្រលប់មកនិយាយពីពិធីនាថ្ងៃនេះវិញ។ រដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់ជំនួយឥតសំណងគូសាណូណិនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩១ ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណូណិ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន ហើយក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុនបានអនុវត្តជាង ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណភាពជីវភាពរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ខ្ញុំសូមណែនាំគម្រោង ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ។

សម្រាប់គម្រោងទី១ ដែលនឹងអនុវត្តដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ២២០,២១៦ ដុល្លារអាមេរិក (ពីររយម្ភៃពាន់ពីររយដប់ប្រាំមួយដុល្លារអាមេរិក) សម្រាប់ការស្តារប្រព័ន្ធធារាសាស្ត្រក្នុងខេត្តបន្ទាយមានជ័យ។ គម្រោងនេះនឹងរួមចំណែកដល់

ការផ្គត់ផ្គង់ទឹកសម្រាប់កសិកម្មប្រកបដោយស្ថិរភាពដល់ប្រជាជនមូលដ្ឋានប្រមាណ ៦,០០០នាក់ នៅទូទាំង ៦ភូមិ ដែលនាំមកនូវការកែលម្អរផលិតកម្មកសិកម្ម និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនមូលដ្ឋាន។ បន្ថែមពីនេះ យើងរំពឹងថាគម្រោងនេះនឹងគាំទ្រដល់ឱកាសការងារផ្នែកកសិកម្មសម្រាប់ប្រជាជនកម្ពុជាដែលបានត្រឡប់មកពីប្រទេសថៃវិញ ដោយសារស្ថានភាពព្រំដែនកម្ពុជា-ថៃ។

សម្រាប់គម្រោងទី២ ដែលនឹងអនុវត្តដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ៨១,៦៨៨ ដុល្លារអាមេរិក (ប៉ែតសិបមួយពាន់ប្រាំមួយរយប៉ែតសិបប្រាំបីដុល្លារអាមេរិក) ដើម្បីសាងសង់អន្តេវាសិកដ្ឋាននិស្សិតស្រី និងផ្តល់ឧបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈថ្មីៗ។ អន្តេវាសិកដ្ឋាននឹងផ្តល់ឱ្យនិស្សិតស្រីនូវកន្លែងស្នាក់នៅប្រកបដោយផាសុកភាព ហើយឧបករណ៍ថ្មីនឹងផ្តល់ឱ្យនិស្សិតទាំងអស់នូវឱកាស ដើម្បីរៀននូវជំនាញវិជ្ជាជីវៈនានា ដែលនឹងជួយពួកគេក្នុងការស្វែងរកការងារបន្ទាប់ពីបញ្ចប់ការសិក្សា។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានសង្កេតឃើញការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជានាពេលថ្មីៗនេះ។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមជាច្រើន ដែលដែលត្រូវដោះស្រាយ ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។ ក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង "គូសាណូណិ" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណច្រើនសម្រាប់ការយកចិត្តទុកដាក់ស្តាប់។